ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
======

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
======

# ស្ថានទូតកម្ពុជានៅម៉ាឡេស៊ី អន្តរាគមជួយពលករ-ពលការិនីខ្មែរ៣នាក់

------------

ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេស**ម៉ាឡេស៊ី** បានអន្តរាគមដោះស្រាយបញ្ហា និងរៀបចំមាតុភូមិនិវត្តន៍របស់ពលករ-ពលការិនីខ្មែរចំនួន**៣នាក់** ដូចខាងក្រោម៖

**(១)** ពលករ **ស.ប.ឱ** អាយុ២៧ឆ្នាំ មកពីស្រុកស្មាច់មានជ័យ ខេត្តកោះកុង បានទៅម៉ាឡេស៊ីខុសច្បាប់ដោយខ្លួនឯង កាលពីថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦។

**(២)** ពលករ **ស.ណ.ស** អាយុ២៥ឆ្នាំ មកពីស្រុកទឹកឈូ ខេត្តកំពត បានទៅម៉ាឡេស៊ីខុសច្បាប់ដោយខ្លួនឯង កាលពីថ្ងៃទី២២ ខែសីហា ឆ្នាំ ២០១៦។

ដោយចង់ត្រឡប់មកកម្ពុជាវិញ ពលករទាំង២នាក់ បានស្នើការអន្តរាគមន៍ពីស្ថានទូតនៅថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៧។ ស្ថានទូតបានសម្របសម្រួលជាមួយការិយាល័យអន្តោប្រវេសន៍ម៉ាឡេស៊ី ដើម្បីអាចរៀបចំមាតុភូមិនិវត្តន៍សម្រាប់ពួកគេ។

ពលករ **ស.ប.ឱ** និង **ស.ណ.ស** នឹងមកដល់អាកាសយានដ្ឋានអន្តរជាតិ**ភ្នំពេញ** នៅថ្ងៃទី**១៣** ខែ**ឧសភា** ឆ្នាំ**២០១៧** វេលាម៉ោង **០៧:៣៥**នាទីព្រឹក តាមជើងយន្តហោះAK536 ។

**(៣)** ពលការិនី **ភ.ស.គ** អាយុ៣៥ឆ្នាំ មកពីខេត្តកំពង់ឆ្នាំង បានទៅម៉ាឡេស៊ីដោយខុសច្បាប់តាមរយៈមេខ្យល់ និងធ្វើការតាមផ្ទះនៅរដ្ឋ Kedah កាលពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧ ។ ដោយសារការងារលំបាក នាងបានលួចចាកចេញពីផ្ទះនិយោជក ហើយត្រូវបានពលរដ្ឋខ្មែរ-ឥស្លាមម្នាក់ ទទួលឱ្យស្នាក់នៅបណ្តោះអាសន្ន និងនាំទៅស្ថានទូតនៅថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៧ ។

ស្ថានទូតបានសម្របសម្រួលជាមួយការិយាល័យអន្តោប្រវេសន៍ម៉ាឡេស៊ី ដើម្បីអាចរៀបចំមាតុភូមិនិវត្តន៍របស់ពលការិនីមកកម្ពុជាវិញ។

ពលការិនី **ភ.ស.គ** បានមកដល់អាកាសយានដ្ឋានអន្តរជាតិ**ភ្នំពេញ** នៅថ្ងៃទី០៨ ខែ**ឧសភា** ឆ្នាំ**២០១៧** វេលាម៉ោង**១៧:៣៥**នាទី តាមជើងយន្តហោះ MH762 ៕

ភ្នំពេញ, ថ្ងៃទី១២ ខែ ឧសភា ឆ្នាំ ២០១៧

**ជុំ សុន្ទរី**
**អ្នកនាំពាក្យ**
ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ